**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៧៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការចេញផ្លាកលេខសម្គាល់យានជំនិះ

ឍ ឍ ឍ ឍ ឍ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ /នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញក្រឹត្យលេខ ៦៨ ក្រ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ១៩៩១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីចរាចរផ្លូវគោក
- បានឃើញអនុក្រឹត្យលេខ ១៤ អនក្រ-បក ចុះថ្ងៃទី ០៣ ខែ មិនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ ០៨ អនក្រ បក ចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ ១៩៩៩ ស្តីពីការផ្តល់ប័ណ្ណសំគាល់យានយន្តផ្លូវគោក
- អនុលោមតាមកិច្ចព្រមព្រៀង ក្នុងក្របខ័ណ្ឌអាស៊ាន ចុះថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ១៩៩៨ និងក្របខ័ណ្ឌមហាអនុតំបន់ទន្លេមេគង្គ ចុះថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៩
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី នាសម័យប្រជុំពេញអង្គ ថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៣

# ស ំ រេ ច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១ .-**

អនុក្រឹត្យនេះមានគោលបំណង ៖

- បង្កការងាយស្រួលក្នុងការគ្រប់គ្រងយានយន្តគ្រប់ប្រភេទ ក្នុងព្រះរាជាណាចក្រកម្ពុជា
- បែងចែកច្បាស់លាស់ នូវប្រភេទម្ចាស់កម្មសិទ្ធិយានយន្ត និងប្រភេទយានយន្ត
- កំណត់ និងផ្ដល់កម្មសិទ្ធិស្របច្បាប់ជូនម្ចាស់យានយន្ត
- ធានាសន្តិសុខ សណ្ដាប់ធ្នាប់ និងរបៀបរៀបរយសង្គម ។

**មាត្រា ២ .-**

អនុក្រឹត្យនេះ មានវិសាលភាពគ្របដណ្ដប់លើរូបវន្តបុគ្គល ឬនីតិបុគ្គល ដែលជាម្ចាស់យានយន្តគ្រប់ប្រភេទក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៣ .-**

ដើម្បីអនុវត្តអនុក្រឹត្យនេះ ពាក្យដូចខាងក្រោម ត្រូវកំណត់និយមន័យដូចតទៅ ៖

- **រថយន្តដឹកទំនិញស្រាល** គឺជារថយន្តដែលមានទម្ងន់សរុបស្មើ ឬ តិចជាង ៣(បី) តោនកន្លះ
- **រថយន្តដឹកទំនិញធ្ងន់** គឺជារថយន្តដែលមានទម្ងន់សរុបលើសពី ៣ ( បី ) តោនកន្លះ
- **ក្បាលរថយន្តសណ្ដោង** គឺជារថយន្តសម្រាប់សណ្ដោង សីមីរ៉ឺម៉ក
- **សីមី រ៉ឺម៉ក** គឺជាយានសម្រាប់ផ្ដក់ជាប់នឹងក្បាលរថយន្តសណ្ដោង
- **រ៉ឺម៉ក** គឺជាយានសម្រាប់ផ្ដក់ជាមួយរថយន្ត
- **យានយន្តបរិក្ខារណ៍** គឺជាយានយន្តពិសេស ដែលបំពាក់គ្រឿងចក្រដោយគ្មានផ្ទុក ទំនិញ ឬ មនុស្សនៅខាងក្រៅកាប៊ីន ជាអាទិ៍ រថយន្តស្ទូច លាយស៊ីម៉ង់ឬរថយន្តដែលភ្ជាប់ដោយ ឧបករណ៍ សម្រាប់ បម្រើការងារសាងសង់ វិស័យកសិកម្ម ឧស្សាហកម្ម ឬទេសចរណ៍
- **ត្រាក់ទ័រ ឬ គោយន្ត** គឺជាយានយន្តសម្រាប់បម្រើការងារកសិកម្ម
- **យានយន្តជាកម្មសិទ្ធិបណ្ដោះអាសន្ន** គឺជាយានយន្តដែលត្រូវបានអនុញ្ញាតឱ្យនាំចូល និង ប្រើប្រាស់មួយរយៈពេលកំណត់
- **អក្សរដើម** គឺអក្សរកាត់ ឬអក្សរពេញតួដែលដាក់នៅមុខលេខសម្គាល់យានយន្ត

- **លេខកូដ** គឺលេខមួយខ្ទង់ ឬ ពីរខ្ទង់ ដែលដាក់នៅមុខលេខសម្គាល់យានយន្ត ។លេខកូដជាប់អក្សរដើមផ្នែកខាងលើ សម្រាប់សម្គាល់ស្ថាប័នគ្រប់គ្រង ឬ ម្ចាស់កម្មសិទ្ធិ ជារូបវន្តបុគ្គលនិងលេខកូដ ជាប់ខាងឆ្វេងលេខសម្គាល់យានយន្តសម្រាប់សម្គាល់ប្រភេទយានយន្ត

- **លេខសម្គាល់យានយន្ត** គឺជាលេខចុះបញ្ជីដែលមានចំនួនបីខ្ទង់ឬបួនខ្ទង់ទៅតាមប្រភេទម្ចាស់កម្មសិទ្ធិ ដាក់នៅពីក្រោយ ឬពីក្រោមអក្សរដើម

- **ការផ្ទេរកម្មសិទ្ធិយានយន្ត** គឺជាការផ្ទេរ ការទទួលខុសត្រូវ កាតព្វកិច្ច និងសិទ្ធិជាម្ចាស់យានយន្តពីម្ចាស់កម្មសិទ្ធិចាស់ទៅម្ចាស់កម្មសិទ្ធិថ្មី ។

## ជំពូកទី ២

## ប្រភេទយានយន្ត ផ្លាកលេខ ម្ចាស់គ្រប់គ្រង និងម្ចាស់កម្មសិទ្ធិយានយន្ត

**មាត្រា ៤ .-**

យានយន្តត្រូវបានចែកចេញជា ៦ប្រភេទដូចខាងក្រោម ៖

ប្រភេទទី ១ : ទោចក្រយានយន្ត - ត្រីចក្រយានយន្ត - ទោចក្រយានយន្តសណ្តោងរ៉ឺម៉ក

ប្រភេទទី ២ : រថយន្តធុនស្រាល

ប្រភេទទី ៣ : រថយន្តធុនធ្ងន់ និងក្បាលរថយន្តសណ្តោង

ប្រភេទទី ៤ : រ៉ឺម៉ក និងសឺមីរ៉ឺម៉ក

ប្រភេទទី ៥ : យានយន្តប្បករណ៍

ប្រភេទទី ៦ : ត្រាក់ទ័រ ឬគោយន្ត ។

**មាត្រា ៥ .-**

ម្ចាស់គ្រប់គ្រង និងម្ចាស់កម្មសិទ្ធិយានយន្ត ត្រូវបានចែកចេញជា ៨ ក្រុមដូចខាងក្រោម ៖

ក្រុមទី ១ : ម្ចាស់គ្រប់គ្រងយានយន្តជារបស់ព្រះបរមរាជវាំង

ក្រុមទី ២ : ម្ចាស់គ្រប់គ្រងយានយន្តជារបស់ក្រសួងស្ថាប័នរដ្ឋ សហគ្រាសសាធារណៈ និងអង្គភាពស្វ័យភិបាលសេដ្ឋកិច្ច

ក្រុមទី ៣ : ម្ចាស់គ្រប់គ្រងយានយន្តជារបស់ក្រសួងការពារជាតិ ប្រើប្រាស់សម្រាប់នៅសមរភូមិ និងការងារការពារជាតិ

ក្រុមទី ៤ : ម្ចាស់គ្រប់គ្រងយានយន្ត ជារបស់ក្រសួងមហាផ្ទៃ ប្រើប្រាស់សម្រាប់ ការងារសន្តិសុខ ឬ សណ្តាប់ធ្នាប់សង្គម

ក្រុមទី ៥ : ម្ចាស់គ្រប់គ្រងយានយន្ត ជារបស់គណកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលជាស្ថាប័ន ឯករាជ្យ

ក្រុមទី ៦ : ម្ចាស់កម្មសិទ្ធិយានយន្ត ជារបស់ស្ថានទូត អង្គការសហប្រជាជាតិ អង្គការអន្តរជាតិ និងអង្គការក្រៅរដ្ឋាភិបាលបរទេស

ក្រុមទី ៧ : ម្ចាស់កម្មសិទ្ធិយានយន្តជារបស់ឯកជនជារូបវន្តបុគ្គល ឬនីតិបុគ្គល

ក្រុមទី ៨ : ម្ចាស់កម្មសិទ្ធិយានយន្តជាបណ្តោះអាសន្នរបស់ រូបវន្តបុគ្គល ឬនីតិបុគ្គល ។

**មាត្រា ៦ ៈ**

ផ្លាកលេខយានយន្តមាន ៩ ប្រភេទ មានអក្សរដើមជាអក្សរខ្មែរ និង អក្សរឡាតាំង លេខកូដ លេខសម្គាល់ និង ពណ៌ ដូចខាងក្រោម ៖

ប្រភេទទី ១ : រាជវាំង 001 ផ្ទៃពណ៌បៃតងចាស់ អក្សរនិងលេខ ពណ៌ទឹកមាស

ប្រភេទទី ២ : រដ្ឋ 01. 2- 0001 ផ្ទៃពណ៌បៃតងខ្ចី អក្សរនិងលេខពណ៌ស

ប្រភេទទី ៣: ខេមរភូមិន្ទ 01. 2- 0001 ផ្ទៃពណ៌ ខៀវខាងលើ ក្រហមខាងក្រោម ចែកពាក់កណ្តាលស្មើ អក្សរនិងលេខ ពណ៌ស

ប្រភេទទី ៤ : នគរបាល 01. 2- 0001 ផ្ទៃពណ៌ ស អក្សរ និង លេខ ពណ៌ក្រហម

ប្រភេទទី ៥ : គជប 01. 2- 0001 ផ្ទៃពណ៌ ស អក្សរ និង លេខ ពណ៌បៃតងចាស់

ប្រភេទទី ៦ : ១-ស្ថានទូត

ក- CMD 01.2- 001 សម្រាប់រថយន្តឯកអគ្គរាជទូត

ខ- CD 01.2- 001 សម្រាប់រថយន្តអង្គទូត កុងស៊ុល

គ- ផ្លាកពីរប្រភេទខាងលើនេះ មានផ្ទៃពណ៌លឿង អក្សរនិងលេខ ពណ៌ទឹកប៊ិច ។

លេខកូដ 01 ជាលេខសម្គាល់ប្រទេស ។

២- អង្គការសហប្រជាជាតិ

ក- ONU 01.2- 001 សម្រាប់ប្រធានបេសកកម្មអង្គការសហប្រជាជាតិ

ខ- ONU 01.2- 002 សម្រាប់សមាជិកអង្គការសហប្រជាជាតិ និង ចុះលេខរៀងបន្តបន្ទាប់តាមចំនួនរថយន្តរបស់អង្គការនេះ

គ- ផ្លាកពីរប្រភេទខាងលើនេះ មានផ្ទៃពណ៌ខៀវផ្ទៃមេឃ អក្សរនិងលេខ ពណ៌ស ។ លេខកូដ 01 ជាលេខសម្គាល់ស្ថាន តំណាងនៃសកម្មភាពការងារ ។

៣- អង្គការអន្តរជាតិ និង អង្គការក្រៅរដ្ឋាភិបាលបរទេស

ក- OI 01.2- 001 សម្រាប់អង្គការអន្តរជាតិ

ខ- ONG 01.2- 001 សម្រាប់អង្គការក្រៅរដ្ឋាភិបាលបរទេស

គ- ផ្លាកលេខពីរប្រភេទខាងលើនេះ មានផ្ទៃពណ៌ខៀវផ្ទៃមេឃ អក្សរនិងលេខ ពណ៌ស ។ លេខកូដ 01 ជាលេខសម្គាល់ឈ្មោះអង្គការអន្តរជាតិ ឬអង្គការក្រៅរដ្ឋាភិបាលបរទេស ។

ប្រភេទទី ៧ : ពណ៌ផ្លាកលេខរបស់ប្រភេទទី៧នេះ គឺ ផ្ទៃពណ៌ស អក្សរ និង លេខពណ៌ខៀវចាស់ ។ អក្សរដើម និងលេខសម្គាល់មានរៀបរាប់ដូចខាងក្រោម ដោយយោងទៅតាមប្រភេទយានយន្តដែលមានចែងក្នុងមាត្រា ៤ខាងលើ :

ក-ទោចក្រយានយន្ត ត្រីចក្រយានយន្ត :ឈ្មោះ ខេត្ត - ក្រុង 1A 0001

ខ-រថយន្តធុនស្រាល :ឈ្មោះ ខេត្ត - ក្រុង 2A 0001

គ-រថយន្តធុនធ្ងន់ និងក្បាលរថយន្តសណ្ដោង :ឈ្មោះ ខេត្ត - ក្រុង 3A 0001

ឃ-រ៉ឺម៉ក និងសីមីរ៉ឺម៉ក :ឈ្មោះ ខេត្ត - ក្រុង 4A 0001

ង-យានយន្តឧបករណ៍ :ឈ្មោះ ខេត្ត - ក្រុង 5A 0001

ច-ត្រាក់ទ័រ ឬ គោយន្ត :ឈ្មោះ ខេត្ត - ក្រុង 6A 0001

ប្រភេទទី ៨ : សម្រាប់រថយន្តនាំចូលបណ្ដោះអាសន្ន AT 01.2- 0001 ផ្ទៃពណ៌លឿងទុំ អក្សរនិងលេខ ពណ៌ស ។

ប្រភេទទី ៩ : ផ្លាកលេខបណ្ដោះអាសន្ន 0001 ផ្ទៃពណ៌លឿង អក្សរ លេខពណ៌ខ្មៅ ។ ផ្លាកលេខនេះប្រើប្រាស់ជាទូទៅ មិនចំពោះក្រុមម្ចាស់កម្មសិទ្ធិមួយណាឡើយ គឺប្រើប្រាស់ជាបណ្ដោះអាសន្នមុនពេលផ្ដល់ប័ណ្ណសម្គាល់យានយន្ត ឬ ប័ណ្ណកម្មសិទ្ធិ និង ផ្លាកលេខពេញសិទ្ធ និងប្រើប្រាស់នៅក្នុងរោងជាងជួសជុលយានយន្តនៅពេលដែលរោងជាងត្រូវការធ្វើការសាកល្បងយានយន្ត ដែលបានជួសជុលរួច ។

**មាត្រា ៧ .-**

ដោយយោងតាមកិច្ចព្រមព្រៀងនៅក្នុង ក្របខ័ណ្ឌមហាអនុតំបន់ទន្លេមេគង្គ រាល់ផ្លាកលេខដែលមានសរសេរអក្សរខ្មែរ ត្រូវមានបកប្រែជាភាសាអង់គ្លេស លើកលែងតែផ្លាកលេខបណ្ដោះអាសន្ន ។

រូបភាព នៃផ្លាកលេខយានយន្តគ្រប់ប្រភេទមានបង្ហាញ ក្នុងឧបសម្ព័ន្ធភ្ជាប់ជាមួយអនុក្រឹត្យនេះ ។

**មាត្រា ៨ .-**

ផ្លាកលេខរបស់ក្រុមទី ១ ដូចមានចែងក្នុងមាត្រា ៥ សម្រាប់យានយន្តព្រះបរមរាជវាំងប្រើប្រាស់ជាផ្លូវការតាមការកំណត់របស់ក្រសួងព្រះបរមរាជវាំង ។

**មាត្រា ៩ .-**

ផ្លាកលេខរបស់ក្រុមទី ២ ដូចមានចែងក្នុងមាត្រា ៥ ត្រូវបានបែងចែកឱ្យ ក្រសួង ស្ថាប័ន តាមលេខរៀងបន្តបន្ទាប់ដូចខាងក្រោម ៖

១-រដ្ឋ 01.2-0001 សម្រាប់រថយន្តដែលប្រើប្រាស់ដោយ សមាជិកព្រឹទ្ធសភា

២-រដ្ឋ 02.2-0001 សម្រាប់រថយន្តដែលប្រើប្រាស់ដោយ សមាជិករដ្ឋសភា

៣-រដ្ឋ03.2-0001 សម្រាប់រថយន្តដែលប្រើប្រាស់ដោយ សមាជិករាជរដ្ឋាភិបាល

៤-រដ្ឋ 04.2-0001 សម្រាប់រថយន្តដែលប្រើប្រាស់ដោយ សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ

៥-រដ្ឋ 05.2-0001 សម្រាប់រថយន្តជាសម្បត្តិរដ្ឋ ដែលប្រើប្រាស់ដោយ ទីស្ដីការគណៈរដ្ឋមន្ត្រី

៦-រដ្ឋ 06.2-0001 សម្រាប់រថយន្តជាសម្បត្តិរដ្ឋ ដែលប្រើប្រាស់ដោយ ក្រសួងការពារជាតិ

៧-រដ្ឋ 07.2-0001 សម្រាប់រថយន្តជាសម្បត្តិរដ្ឋ ដែលប្រើប្រាស់ដោយ ក្រសួងមហាផ្ទៃ

៨-រដ្ឋ 08.2-0001 សម្រាប់រថយន្តជាសម្បត្តិរដ្ឋ ដែលប្រើប្រាស់ដោយ ក្រសួងទំនាក់ទំនង ព្រឹទ្ធសភា រដ្ឋសភា និង អធិការកិច្ច

៩-រដ្ឋ 09.2-0001 សម្រាប់រថយន្តជាសម្បត្តិរដ្ឋ ដែលប្រើប្រាស់ដោយ ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ

១០-រដ្ឋ10.2-0001 សម្រាប់រថយន្តជាសម្បត្តិរដ្ឋ ដែលប្រើប្រាស់ដោយ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

១១-រដ្ឋ11.2-0001 សម្រាប់រថយន្តជាសម្បត្តិរដ្ឋ ដែលប្រើប្រាស់ដោយ ក្រសួងពត៌មាន

១២-រដ្ឋ12.2-0001 សម្រាប់រថយន្តជាសម្បត្តិរដ្ឋ ដែលប្រើប្រាស់ដោយ ក្រសួងសុខាភិបាល

១៣-រដ្ឋ13.2-0001 សម្រាប់រថយន្តជាសម្បត្តិរដ្ឋ ដែលប្រើប្រាស់ដោយ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

១៤-រដ្ឋ14.2-0001 សម្រាប់រថយន្តជាសម្បត្តិរដ្ឋ ដែលប្រើប្រាស់ដោយ ក្រសួងផែនការ

១៥-រដ្ឋ15.2-0001 សម្រាប់រថយន្តជាសម្បត្តិរដ្ឋ ដែលប្រើប្រាស់ដោយ ក្រសួងពាណិជ្ជកម្ម

១៦-រដ្ឋ16.2-0001 សម្រាប់រថយន្តជាសម្បត្តិរដ្ឋ ដែលប្រើប្រាស់ដោយ ក្រសួងអប់រំយុវជននិងកីឡា

១៧-រដ្ឋ17.2-0001 សម្រាប់រថយន្តជាសម្បត្តិរដ្ឋ ដែលប្រើប្រាស់ដោយ ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ

១៨-រដ្ឋ18.2-0001 សម្រាប់រថយន្តជាសម្បត្តិរដ្ឋ ដែលប្រើប្រាស់ដោយក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

១៩-រដ្ឋ19.2-0001 សម្រាប់រថយន្តជាសម្បត្តិរដ្ឋ ដែលប្រើប្រាស់ដោយ ក្រសួងបរិស្ថាន

២០-រដ្ឋ20.2-0001 សម្រាប់រថយន្តជាសម្បត្តិរដ្ឋ ដែលប្រើប្រាស់ដោយ ក្រសួងអភិវឌ្ឍន៍ជនបទ

២១-រដ្ឋ21.2-0001 សម្រាប់រថយន្តជាសម្បត្តិរដ្ឋ ដែលប្រើប្រាស់ដោយ ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

២២-រដ្ឋ22.2-0001 សម្រាប់រថយន្តជាសម្បត្តិរដ្ឋ ដែលប្រើប្រាស់ដោយ ក្រសួងប្រៃសណីយ៍និង ទូរគមនាគមន៍

២៣-រដ្ឋ23.2-0001 សម្រាប់រថយន្តជាសម្បត្តិរដ្ឋ ដែលប្រើប្រាស់ដោយ ក្រសួងធម្មការនិងកិច្ចការសាសនា

២៤-រដ្ឋ24.2-0001 សម្រាប់រថយន្តជាសម្បត្តិរដ្ឋ ដែលប្រើប្រាស់ដោយ ក្រសួងកិច្ចការនារីនិងអតីតយុទ្ធជន

២៥-រដ្ឋ25.2-0001 សម្រាប់រថយន្តជាសម្បត្តិរដ្ឋ ដែលប្រើប្រាស់ដោយ ក្រសួងសាធារណការនិងដឹកជញ្ជូន

២៦-រដ្ឋ26.2-0001 សម្រាប់រថយន្តជាសម្បត្តិរដ្ឋ ដែលប្រើប្រាស់ដោយ ក្រសួងយុត្តិធម៌

២៧-រដ្ឋ27.2-0001 សម្រាប់រថយន្តជាសម្បត្តិរដ្ឋ ដែលប្រើប្រាស់ដោយ ក្រសួងទេសចរណ៍

២៨-រដ្ឋ28.2-0001 សម្រាប់រថយន្តជាសម្បត្តិរដ្ឋ ដែលប្រើប្រាស់ដោយ ក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់

២៩-រដ្ឋ29.2-0001 សម្រាប់រថយន្តជាសម្បត្តិរដ្ឋ ដែលប្រើប្រាស់ដោយ ក្រសួងធនធានទឹកនិងឧតុនិយម

៣០-រដ្ឋ30.2-0001 សម្រាប់រថយន្តជាសម្បត្តិរដ្ឋ ដែលប្រើប្រាស់ដោយ ក្រសួងព្រះបរមរាជវាំង

៣១-រដ្ឋ31.2-0001 សម្រាប់រថយន្តជាសម្បត្តិរដ្ឋ ដែលប្រើប្រាស់ដោយ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

៣២-រដ្ឋ32.2-0001 សម្រាប់រថយន្តជាសម្បត្តិរដ្ឋ ដែលប្រើប្រាស់ដោយ រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល

៣៣-រដ្ឋ33.2-0001 សម្រាប់រថយន្តជាសម្បត្តិរដ្ឋ ដែលប្រើប្រាស់ដោយឧត្តមក្រុមប្រឹក្សាអង្គចៅក្រម

៣៤-រដ្ឋ34.2-0001 សម្រាប់រថយន្តជាសម្បត្តិរដ្ឋ ដែលប្រើប្រាស់ដោយអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា អគ្គលេខាធិការដ្ឋានរដ្ឋសភា អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ

៣៥-រដ្ឋ35.2-0001 សម្រាប់រថយន្តជាសម្បត្តិរដ្ឋ ដែលប្រើប្រាស់ដោយ ធនាគារជាតិនៃកម្ពុជា

៣៦-រដ្ឋ36.2-0001 សម្រាប់រថយន្តជាសម្បត្តិរដ្ឋ ដែលប្រើប្រាស់ដោយ អង្គការរបស់ជាតិ

៣៧-រដ្ឋ37.2-0001 ដល់ រដ្ឋ61.2-0001 សម្រាប់រថយន្តជាសម្បត្តិរដ្ឋ ដែលប្រើប្រាស់ដោយ ខេត្ត-ក្រុងទូទាំងប្រទេស ។

ចំពោះអគ្គលេខាធិការដ្ឋាន អាជ្ញាធរជាតិ សហគ្រាសសាធារណៈនិងអង្គភាពស្វ័យភិបាលសេដ្ឋកិច្ច ដែលចំណុះនៅក្នុងក្រសួង ស្ថាប័នណា ត្រូវយកចង្កោមលេខរបស់ក្រសួង ស្ថាប័ននោះមកប្រើប្រាស់ ។

ក្នុងករណីមានការប្រែប្រួលចំនួនក្រសួងស្ថាប័នទៅថ្ងៃអនាគត ក្រសួងសាធារណការ និងដឹកជញ្ជូនត្រូវចេញប្រកាសលម្អិតបន្ថែមអំពីការប្រែប្រួលនេះ ។

រដ្ឋមន្ត្រីក្រសួងសាធារណការ និង ដឹកជញ្ជូន និង រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវចេញប្រកាសអន្តរក្រសួងលម្អិតអំពីការគ្រប់គ្រងយានយន្តប្រភេទខាងលើនេះឱ្យបានល្អ ។

**មាត្រា ១០ ._**

- យានយន្តដែលប្រើប្រាស់ដោយ សមាជិកព្រឹទ្ធសភា សមាជិករដ្ឋសភា សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ សមាជិករាជរដ្ឋាភិបាល មន្ត្រីកងយោធពលខេមរភូមិន្ទ មន្ត្រីនគរបាល ដែលបានមកដោយប្រើប្រាស់ថវិការដ្ឋ ត្រូវពាក់ផ្លាកលេខ រដ្ឋ ។

- យានយន្តដែលបានមកដោយថវិកាឯកជនរបស់ សមាជិកព្រឹទ្ធសភា សមាជិករដ្ឋសភា សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ សមាជិករាជរដ្ឋាភិបាល មន្ត្រីកងយោធពលខេមរភូមិន្ទ មន្ត្រីនគរបាល ត្រូវពាក់ផ្លាកលេខឯកជន ។

- នៅក្នុងអាណត្តិរបស់ខ្លួន យានយន្តរបស់សមាជិកព្រឹទ្ធសភា សមាជិករដ្ឋសភាដែលពាក់ផ្លាកលេខឯកជន ត្រូវបិទសញ្ញា ព្រឹទ្ធសភា ឬ រដ្ឋសភា ។

**មាត្រា ១១ ._**

យានយន្តក្នុងក្រុមទី ៣ ដែលមានចែងក្នុងមាត្រា ៥ ខាងលើ គឺប្រើប្រាស់ ជាមធ្យោបាយសម្រាប់ដឹកជញ្ជូនសម្ភារៈទ័ព ឬ ដឹកជញ្ជូនកងទ័ព ។ យានយន្តទាំងនោះត្រូវលាបពណ៌គ្រៃអ៊ី ឬជាពណ៌អ្វីផ្សេងដែលជាពណ៌ពិសេសសម្រាប់កងទ័ព តាមការកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ។

នៅជញ្ជាំងទ្វារខាងមុខទាំងសងខាង ត្រូវរចនាសញ្ញាសម្គាល់របស់កងទ័ព និងមានអក្សរ កងខេមរភូមិន្ទ ជាអក្សរឡាតាំង R C A F (Royal Cambodian Armed Forces ) ដាក់នៅ ក្រោម អក្សរ ខ្មែរ ឬ នៅលើតួយានយន្ត។ ទំហំផ្លាកអក្សរ និង លេខ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ ។

**មាត្រា ១២ ._**

យានយន្តក្នុងក្រុមទី ៤ ដែលមានចែងក្នុងមាត្រា ៥ ខាងលើ គឺជាយានយន្តដែលប្រើប្រាស់ជាមធ្យោបាយសម្រាប់ការងារការពារសន្តិសុខជាតិ និង សណ្តាប់ធ្នាប់សង្គម ។ យានយន្តប្រភេទនេះ ត្រូវលាបពណ៌ ពិសេស ដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នៅជញ្ជាំងទ្វារសងខាង ត្រូវមានរចនារូបសញ្ញារបស់នគរបាលជាតិ និង សរសេរអក្សរ នគរបាលជាតិ ជាអក្សរឡាតាំង POLICE ដាក់នៅក្រោមអក្សរខ្មែរ ឬ នៅលើតួយានយន្ត។ទំហំអក្សរ លេខ និង ផ្លាក ត្រូវកំណត់ដោយប្រកាសរបស់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា ១៣ ._**

យានយន្តក្នុងក្រុមទី៥ ដូចមានចែងក្នុងមាត្រា៥ ខាងលើសម្រាប់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវពាក់ផ្លាកលេខ គជប 01. 2-0001 ។ ក្រសួងសាធារណការនិង ដឹកជញ្ជូន ត្រូវចេញប្រកាសលម្អិតអំពីនីតិវិធីប្រើប្រាស់ និងគ្រប់គ្រងផ្លាកលេខនេះ ។

**មាត្រា ១៤ ._**

១- យានយន្តចែងក្នុងក្រុម ទី ៦ នៃមាត្រា ៥ ខាងលើ ត្រូវមានលេខសម្គាល់ដូចខាងក្រោម ៖

ក- លេខកូដសម្គាល់ស្ថានទូត ឬកុងស៊ុល យោងតាមលំដាប់ នៃកាលបរិច្ឆេទ នៃការបើកស្ថានបេសកកម្មការទូត

ខ- លេខកូដសម្គាល់ ស្ថានតំណាង នៃបេសកកម្មអង្គការសហប្រជាជាតិ យោងតាមលំដាប់នៃកាលបរិច្ឆេទសកម្មភាពការងារ

គ- លេខកូដសម្គាល់ អង្គការអន្តរជាតិ យោងតាមលំដាប់កាលបរិច្ឆេទចុះហត្ថលេខាលើកិច្ចព្រមព្រៀងជាមួយរាជរដ្ឋាភិបាល

ឃ- លេខកូដសម្គាល់ អង្គការក្រៅរដ្ឋាភិបាលបរទេស យោងតាមលំដាប់កាលបរិច្ឆេទចុះហត្ថលេខាលើអនុស្សរណៈ ជាមួយរាជរដ្ឋាភិបាល ។

២- រដ្ឋមន្ត្រី ក្រសួងសាធារណការ និង ដឹកជញ្ជូន និង រដ្ឋមន្ត្រី ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ ត្រូវចេញប្រកាសអន្តរក្រសួងលម្អិតអំពីការគ្រប់គ្រង និង តាមដានផ្លាកលេខប្រភេទនេះ ឱ្យល្អប្រសើរ ។

**មាត្រា ១៥._**

យានយន្តក្នុងក្រុមទី ៧ ដូចចែងក្នុងមាត្រា ៥ ខាងលើគឺជាយានយន្តរបស់ឯកជន ជារូបវន្តបុគ្គល ឬ នីតិបុគ្គល ។ លេខ 1 ដល់ លេខ 6 ដាក់នៅពីមុខព្យញ្ជនៈ A-B-C...Z គឺជាលេខសម្គាល់ប្រភេទយានយន្តដូចមានចែងនៅក្នុងមាត្រា ៤ ។ អក្សរព្យញ្ជនៈ A-B-C...Z គឺព្យញ្ជនៈរៀង នៃលេខសម្គាល់របស់យានយន្ត ។ នៅពេលលេខ A.0001

មានលេខ ដល់ A.9999 ព្យញ្ជនៈនេះ ត្រូវប្តូរតាមលំដាប់ព្យញ្ជនៈB-C-D...Z ។ នៅពេលចប់ព្យញ្ជនៈ Z តែតម្រូវការផ្លាក់លេខនៅតែមានបន្តទៀត ត្រូវចាប់ផ្តើមបន្ថែមព្យញ្ជនៈមួយទៀត គឺ AA 0001 - AB 0001 ...AZ 0001 ហើយធ្វើរបៀបដូចនេះជាបន្តបន្ទាប់ ។

**មាត្រា ១៦.-**

១-យានយន្តក្នុងក្រុមទី ៨ ដូចមានចែងក្នុងមាត្រា ៥ ខាងលើ លេខពីរខ្ទង់ដាក់បន្ទាប់ពីអក្សរ AT ជាលេខសម្គាល់ឆ្នាំដែលផ្តល់ផ្លាកលេខ ។ ប័ណ្ណសម្គាល់យានយន្តនៅក្នុងក្រុមទី៨ នេះមានសុពលភាពតែមួយឆ្នាំគត់ហើយត្រូវអស់សុពលភាពនៅថ្ងៃទី ៣១ ធ្នូ ទោះជាយានយន្តនោះត្រូវបានចុះបញ្ជីនៅខែណាមួយ នៃឆ្នាំផ្តល់ប័ណ្ណនោះក៏ដោយ ។

២-រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន និង រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវចេញប្រកាសអន្តរក្រសួងលម្អិតអំពីការគ្រប់គ្រងត្រួតពិនិត្យ និង តាមដានយានយន្តដែលនៅក្នុងក្រុមទី៨នេះ ។

## ជំពូក ទី៣

## លក្ខខណ្ឌ នៃការប្រើប្រាស់ផ្លាកលេខ និង ប័ណ្ណសម្គាល់យានយន្ត

**មាត្រា ១៧ .-**

១- ទោចក្រយានយន្ត និងត្រីចក្រយានយន្ត ត្រូវមានផ្លាកលេខមួយនៅខាងក្រោយយានយន្ត ។

២- ទោចក្រយានយន្តសណ្តោងរ៉ឺម៉ក រ៉ឺម៉កម៉ូតូ ត្រូវមានផ្លាកមួយ ជាប់ខាងក្រោយទោចក្រយានយន្ត និងត្រូវមានផ្លាកលេខបន្ថែមមួយទៀត ដាក់នៅផ្នែកខាងក្រោយរ៉ឺម៉ក ដែលជាលេខសម្គាល់របស់ទោចក្រយានយន្ត ។

៣- យានយន្តប្បករណ៍ ត្រាក់ទ័រ និង រថយន្តគ្រប់ប្រភេទត្រូវមានផ្លាកលេខខាងមុខមួយនិងផ្លាកលេខខាងក្រោយមួយ ។

៤- នៅពេលធ្វើចរាចរ រ៉ឺម៉ក និង សឺមីរ៉ឺម៉កត្រូវពាក់ផ្លាកលេខ នៅផ្នែកខាងក្រោយមួយ និងត្រូវពាក់ផ្លាកលេខមួយទៀតដែលជាផ្លាកលេខរបស់រថយន្តសណ្តោង ។ ផ្លាកលេខនេះត្រូវដាក់ទន្ទឹមគ្នា និងនៅខាងឆ្វេង នៃផ្លាកលេខរ៉ឺម៉ក ឬ សឺមីរ៉ឺម៉កនោះ ។

៥- ផ្លាកលេខយានយន្តគ្រប់ប្រភេទ ត្រូវចាប់ភ្ជាប់ទៅនឹងយានយន្ត ក្នុងលក្ខណៈមួយដែលមិនអាចដោះចេញវិញបានដោយងាយស្រួល និងដោយគ្មានស្លាកស្នាមរបេក ។

**មាត្រា ១៨ .-**

១-ហាមប្រើប្រាស់ផ្លាកលេខ ដែលច្នៃប្រឌិតដោយខ្លួនឯង និង តុបតែងផ្កាភ្លើ ធ្វើឱ្យមានការលំបាកក្នុងការមើលឃើញលេខ និង អក្សរ របស់ផ្លាកលេខ ។

២-ផ្លាកលេខ ត្រូវពាក់នៅកន្លែងដែលងាយស្រួលមើលឃើញ និង មានសភាពស្អាតជានិច្ច ។

៣-ហាមដាក់សម្ភារៈ ឬ វត្ថុផ្សេងៗ ដែលធ្វើឱ្យបាំងផ្លាកលេខ ។

**មាត្រា ១៩ .-**

ទំហំប័ណ្ណសម្គាល់យានយន្ត ខ្លឹមសារនៃប័ណ្ណទំហំផ្លាកលេខ កម្រាស់ និង កម្ពស់អក្សរនិងលេខ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន ។

**មាត្រា ២០ .-**

នៅពេលយានយន្តបាននាំចេញទៅក្រៅព្រះរាជាណាចក្រកម្ពុជា ឬ យានយន្តដែលខូចប្រើប្រាស់លែងកើត ទោះជាដោយមូលហេតុណាមួយក៏ដោយ ម្ចាស់យានយន្ត ជារូបវន្តបុគ្គល ឬ ជានីតិបុគ្គល ឬ ក្រសួង ស្ថាប័ន ឬ អង្គការផ្សេងៗ ត្រូវយកផ្លាកលេខ និង ប័ណ្ណសម្គាល់យានយន្តភ្ជាប់ជាមួយលិខិតបញ្ជាក់អំពីមូលហេតុដែលយានយន្តត្រូវបាននាំចេញទៅក្រៅប្រទេសឬត្រូវខូចប្រើប្រាស់លែងកើត ជូនមកអគ្គនាយកដ្ឋានដឹកជញ្ជូន ឬមន្ទីរសាធារណការនិងដឹកជញ្ជូនខេត្ត ក្រុង ក្នុងរយៈពេលយ៉ាងយូរ ៣០ ថ្ងៃបន្ទាប់ពីយានយន្តត្រូវខូច ឬ នាំចេញទៅប្រទេសដទៃ ។ ក្នុងករណីមានការលំបាកម្ចាស់យានយន្តអាចយកទៅប្រគល់ជូនអាជ្ញាធរមានសមត្ថកិច្ច ឃុំ សង្កាត់របស់ខ្លួនបាន ។ ក្នុងករណីនេះ អាជ្ញាធរមានសមត្ថកិច្ច ឃុំ សង្កាត់ ត្រូវបញ្ជូនផ្លាកលេខ ប័ណ្ណសម្គាល់យានយន្ត និង របាយការណ៍របស់ម្ចាស់យានយន្ត មកអគ្គនាយកដ្ឋានដឹកជញ្ជូន ឬ មន្ទីរសាធារណការ និង ដឹកជញ្ជូន ខេត្ត ក្រុង តាមគ្រប់មធ្យោបាយដែលអាចធ្វើទៅបាន ។

មន្ទីរសាធារណការនិងដឹកជញ្ជូនខេត្ត ក្រុង ត្រូវបញ្ជូនបន្តមកអគ្គនាយកដ្ឋានដឹកជញ្ជូន ក្រសួងសាធារណការនិងដឹកជញ្ជូន ដើម្បីធ្វើការគ្រប់គ្រង បូកសរុប ធ្វើការគណនារកចំនួនយានយន្តពិតប្រាកដដែលកំពុងធ្វើចរាចរ ។

**មាត្រា ២១ .-**

១- យានយន្តមួយគ្រឿងត្រូវមានលេខសម្គាល់គឺលេខចុះបញ្ជីតែមួយគត់ ។ លេខសម្គាល់នេះត្រូវប្រើប្រាស់រហូតដល់យានយន្តត្រូវខូចប្រើប្រាស់មិនបាន ឬនាំចេញទៅក្រៅព្រះរាជាណាចក្រកម្ពុជា ។

២-ហាមប្តូរលេខសម្គាល់យានយន្ត លើកលែងតែ យានយន្តនោះត្រូវបានផ្លាស់ប្តូរម្ចាស់កម្មសិទ្ធិ ដែលនៅខេត្ត ក្រុងផ្សេងគ្នា ។

៣-ក្នុងករណីដែលយានយន្តមួយបានប្តូរម្ចាស់គ្រប់គ្រង ឬម្ចាស់កម្មសិទ្ធិទៅខេត្តក្រុងមួយផ្សេងរួចហើយៗក្រោយមកយានយន្តនេះ បានផ្ទេរម្ចាស់គ្រប់គ្រង ឬ ម្ចាស់កម្មសិទ្ធិថ្មីជាលើកទី២ដែលមានអាសយដ្ឋាននៅខេត្ត ក្រុងដើមវិញ ក្នុងករណីនេះ យានយន្តនេះត្រូវយកលេខសម្គាល់ចាស់មកប្រើប្រាស់វិញ ។

**មាត្រា ២២ .-**

១-ក្នុងករណីយានយន្តត្រូវលក់ ឬ ធ្វើជាអំណោយទៅបុគ្គលណាមួយផ្សេងទៀត ម្ចាស់គ្រប់គ្រង ឬ ម្ចាស់កម្មសិទ្ធិយានយន្ត ត្រូវដាក់ពាក្យសុំធ្វើការកាត់ឈ្មោះផ្ទេរកម្មសិទ្ធិ តាមច្បាប់ជាធរមាន នៅអគ្គនាយកដ្ឋានដឹកជញ្ជូន ឬ នៅមន្ទីរសាធារណការ និងដឹកជញ្ជូន ខេត្ត -ក្រុង ។

២-ចំពោះយានយន្តដែលម្ចាស់គ្រប់គ្រង ឬ ម្ចាស់កម្មសិទ្ធិ ជាក្រុមហ៊ុន ជានីតិបុគ្គល អាចធ្វើការផ្ទេរកម្មសិទ្ធិ បានលុះត្រាតែមានឯកសារស្របច្បាប់បញ្ជាក់ពីការផ្ទេរកម្មសិទ្ធិនោះ ។

**មាត្រា ២៣ .-**

បណ្ណសម្គាល់យានយន្តនិងផ្លាកលេខត្រូវធ្វើការផ្លាស់ប្តូរនូវចំណុចមួយចំនួនទៅតាមករណីដូចខាងក្រោម—៖

ក- ក្នុងការកាត់ឈ្មោះ ផ្ទេរកម្មសិទ្ធិ បណ្ណសម្គាល់យានយន្តត្រូវប្តូរដោយដាក់ឈ្មោះម្ចាស់គ្រប់គ្រង និង ម្ចាស់កម្មសិទ្ធិថ្មី និង អាស័យដ្ឋានរបស់ម្ចាស់គ្រប់គ្រង ឬ ម្ចាស់កម្មសិទ្ធិថ្មី ។

ខ- ក្នុងករណី ម្ចាស់គ្រប់គ្រង ឬ ម្ចាស់កម្មសិទ្ធិបានផ្លាស់ប្តូរអាស័យដ្ឋានដែលនៅក្នុង ខេត្ត ក្រុង ដដែល បណ្ណសម្គាល់យានយន្តត្រូវផ្លាស់ប្តូរដោយដាក់តែអាស័យដ្ឋានថ្មីប៉ុណ្ណោះ ។

គ- ក្នុងករណី ម្ចាស់គ្រប់គ្រង ឬ ម្ចាស់កម្មសិទ្ធិបានផ្លាស់ប្តូរអាស័យដ្ឋានទៅនៅខេត្ត ក្រុង ផ្សេង បណ្ណសម្គាល់យានយន្ត និងផ្លាកលេខ ត្រូវប្តូរលេខសម្គាល់យានយន្តគឺលេខចុះបញ្ជីថ្មី ឈ្មោះខេត្ត-ក្រុងថ្មី និងអាស័យដ្ឋានរបស់ម្ចាស់គ្រប់គ្រង ឬ ម្ចាស់យានយន្តថ្មី ។

ឃ- ក្នុងការប្តូរម៉ាស៊ីន ប្តូរពណ៌ បណ្ណសម្គាល់យានយន្តត្រូវប្តូរដោយដាក់លេខម៉ាស៊ីន ឬ ពណ៌ថ្មី ។

**មាត្រា ២៤ .-**

ក្នុងករណីដែលបណ្ណសម្គាល់យានយន្តជ្រុះបាត់ ឬរហែក ឬរលុបអក្សរឬលេខ ឬ ផ្លាកលេខជ្រុះបាត់ បាក់ ឬរលុបអក្សរឬលេខ ម្ចាស់យានយន្តត្រូវអនុវត្តដូចខាងក្រោម ៖

១-ករណីជ្រុះបាត់ ត្រូវដាក់ពាក្យសុំធ្វើទុតិយតានៅអគ្គនាយកដ្ឋានដឹកជញ្ជូន ឬ មន្ទីរសាធារណការ និងដឹកជញ្ជូន ខេត្ត ក្រុង តាមការកំណត់របស់ រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន តាមរយៈនគរបាលនៅកន្លែងដែលជ្រុះបាត់ ឬ នៅកន្លែងលំនៅស្ថានរបស់ខ្លួន ។

២- ករណី បាក់ រហែក រលុបអក្សរឬលេខ ត្រូវដាក់ពាក្យសុំធ្វើទុតិយតា នៅអគ្គនាយកដ្ឋានដឹកជញ្ជូន ឬមន្ទីរសាធារណការដឹកជញ្ជូន ខេត្ត ក្រុង តាមការកំណត់របស់រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន ដោយភ្ជាប់មកជាមួយនូវផ្លាកលេខឬបណ្ណដែលរហែក បាក់ ឬ រលុបអក្សរឬលេខនោះ ។

## ជំពូកទី ៤

## សមត្ថកិច្ចគ្រប់គ្រងយានយន្ត

**មាត្រា ២៥ .-**

១-ក្រសួងសាធារណការ និង ដឹកជញ្ជូន មានសមត្ថកិច្ចគ្រប់គ្រង ចេញបណ្ណសម្គាល់ និង ផ្លាកលេខយានយន្ត ដែលស្ថិតនៅក្នុងក្រុមម្ចាស់គ្រប់គ្រង ទី ១ និង ទី ២ ក្រុមម្ចាស់កម្មសិទ្ធិទី ៥-៦-៧ និងទី ៨ ដែលមានចែងនៅក្នុងមាត្រា ៥ និង ផ្លាកលេខ បណ្តោះអាសន្ន ដែលមានចែងក្នុងមាត្រា ៦ នៃអនុក្រឹត្យនេះ ។

២-ក្រសួងការពារជាតិ មានសមត្ថកិច្ចគ្រប់គ្រងចេញបណ្ណសម្គាល់ និង ផ្លាកលេខយានយន្តដែលស្ថិតនៅក្នុងក្រុមម្ចាស់គ្រប់គ្រងទី ៣ ដែលមានចែងក្នុងមាត្រា ៥ នៃអនុក្រឹត្យនេះ ។

៣-ក្រសួងមហាផ្ទៃ មានសមត្ថកិច្ចគ្រប់គ្រងចេញប័ណ្ណសម្គាល់ និង ផ្លាកលេខយានយន្តដែលស្ថិតនៅក្នុងក្រុមម្ចាស់គ្រប់គ្រងទី៤ ដែលមានចែងក្នុងមាត្រា ៥ នៃអនុក្រឹត្យនេះ ។

៤-ការចេញប័ណ្ណសម្គាល់និងផ្លាកលេខយានយន្តគ្រប់ប្រភេទ អាចធ្វើទៅបាន លុះត្រាតែយានយន្តទាំងនោះត្រូវបាននាំចូលមកក្នុងព្រះរាជាណាចក្រកម្ពុជា ដោយស្របតាមច្បាប់ជាធរមាន និងត្រូវបានបំពេញកាតព្វកិច្ចពន្ធដារនៃការនាំចូលនោះសព្វគ្រប់ហើយ ។

៥- ស្ថាប័នដែលជាសមត្ថកិច្ចខាងលើនេះ ត្រូវផ្ញើបញ្ជីប័ណ្ណសម្គាល់នូវផ្លាកលេខយានយន្ត ដែលស្ថិតនៅក្នុងម្ចាស់គ្រប់គ្រង ដូចមានចែងក្នុងមាត្រា៥ និងមាត្រា៦ នៃអនុក្រឹត្យនេះ មកក្រសួងមហាផ្ទៃ ដើម្បីបំរើការគ្រប់គ្រងសន្តិសុខ និងរបៀបរៀបរយសាធារណៈ ។

**មាត្រា ២៦ .-**

រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវចេញសារាចរណែនាំលម្អិតបន្ថែមស្តីពីការអនុវត្តអនុក្រឹត្យនេះ តាមសមត្ថកិច្ចរៀង១ខ្លួន ។

## ជំពូកទី ៥

## អន្តរប្បញ្ញត្តិ

**មាត្រា ២៧ .-**

១- ក្នុងតំណាក់កាលទីមួយ ចាប់ពីកាលបរិច្ឆេទដែលអនុក្រឹត្យនេះបានចូលជាធរមាន រាល់ការផ្តល់ប័ណ្ណសម្គាល់យានយន្តថ្មីនិងផ្លាកលេខថ្មីដែលមានចែងនៅក្នុងអនុក្រឹត្យនេះ ត្រូវអនុវត្តតែលើយានយន្តថ្មីមិនទាន់ធ្វើការចុះបញ្ជី យានយន្តដែលមានផ្លាកលេខប្រភេទចាស់ហើយមកសុំធ្វើ ការផ្ទេរកម្មសិទ្ធិ ទុតិយតា ប្តូរពណ៌ ប្តូរម៉ាស៊ីន និង ចំពោះម្ចាស់យានយន្តប្រើផ្លាកលេខប្រភេទចាស់ តែមានបំណងសុំប្តូរប័ណ្ណថ្មី និង ផ្លាកលេខថ្មី ។ ដោយឡែក យានយន្តរបស់ព្រឹទ្ធសភា រដ្ឋសភា រាជរដ្ឋាភិបាល ក្រុមប្រឹក្សាធម្មនុញ្ញ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និង ក្រសួង ស្ថាប័នរដ្ឋ ត្រូវប្តូរយកផ្លាកថ្មី ។

២- ក្នុងតំណាក់កាលទី ២ នៅក្នុងរយៈពេល ២ (ពីរ) ឆ្នាំយ៉ាងយូរក្រោយពីអនុក្រឹត្យនេះចូលជាធរមាន ក្រសួងការពារជាតិ ក្រសួងមហាផ្ទៃ ព្រមទាំងម្ចាស់កម្មសិទ្ធិយានយន្តទាំងអស់ដែលមានប័ណ្ណ និង ផ្លាកលេខចាស់ត្រូវប្តូរយកប័ណ្ណ និង ផ្លាកលេខថ្មី ។

៣- ក្រសួងសាធារណការនិងដឹកជញ្ជូន ត្រូវរៀបចំប្រកាស ស្តីអំពីនីតិវិធីនៃការចុះបញ្ជីយានយន្ត និងប្រាក់បន្ទុក ។

៤- ចំពោះរថយន្តដែលឆ្លងកាត់ប្រទេសកម្ពុជា នឹងមានកំណត់ដោយឡែក ។

## ជំពូកទី ៦

## អវសានប្បញ្ញត្តិ

**មាត្រា ២៨ ._**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ២៩ ._**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងខ្លួន ។

**មាត្រា ៣០ ._**

អនុក្រឹត្យនេះចូលជាធរមានចាប់ពីថ្ងៃ ចុះហត្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៨ ខែធ្នូ ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួងស្ថាប័ន
- គ្រប់សាលាខេត្ត ក្រុង
- ដូចមាត្រា ២៩
- ឯកសារ - កាលប្បវត្តិ

# ឧបសម្ព័ន្ធ

## នៃអនុក្រឹតលេខៈ ៧៤ អនក្រ.បក ចុះថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០០៣

## ស្តីពីការចេញផ្លាកលេខសម្គាល់យានជំនិះ

ប្រភេទ ទី១ : យានយន្តគ្រប់គ្រងដោយព្រះបរមរាជវាំង




ប្រភេទ ទី២ : យានយន្ត គ្រប់គ្រងដោយក្រសួងស្ថាប័នរដ្ឋ និងសហគ្រាសសាធារណៈ និងអង្គភាពស្វ័យភិបាលសេដ្ឋកិច្ច ។




ប្រភេទ ទី៣ : យានយន្ត គ្រប់គ្រងដោយក្រសួងការពារជាតិ សំរាប់ប្រើប្រាស់នៅសមរភូមិ និងការងារការពារជាតិ ។



ប្រភេទ ទី៤ : យានយន្តគ្រប់គ្រងដោយក្រសួងមហាផ្ទៃ ប្រើប្រាស់សំរាប់ការងារសន្តិសុខ សណ្តាប់ធ្នាប់សង្គម




ប្រភេទ ទី៥ : យានយន្តគ្រប់គ្រងដោយគណៈកម្មាធិការជាតិគ្រប់គ្រងការបោះឆ្នោត




ប្រភេទ ទី៦ : យានយន្តជាកម្មសិទ្ធិរបស់ស្ថានទូត និងអង្គការសហប្រជាជាតិ

១-យានយន្តជាកម្មសិទ្ធិរបស់ស្ថានទូត

ក-សំរាប់ឯកអគ្គរាជទូត



ខ-សំរាប់អង្គទូត ឬកុងស៊ុល




២-យានយន្តជាកម្មសិទ្ធិរបស់អង្គការសហប្រជាជាតិ

ក- ប្រធានបេសកកម្ម




ខ- សមាជិក



៣ - យានយន្តជាកម្មសិទ្ធិរបស់អង្គការអន្តរជាតិ និង អង្គការក្រៅរដ្ឋាភិបាលបរទេស

ក- សំរាប់អង្គការអន្តរជាតិ




ខ- សំរាប់អង្គការក្រៅរដ្ឋាភិបាល




**ប្រភេទ ទី៧ :** យានយន្តជាកម្មសិទ្ធិរបស់ឯកជនជាបុគ្គល ឬនិតិបុគ្គល

ក-ទោចក្រយានយន្ត ត្រីចក្រយានយន្ត



ខ-រថយន្តធុនស្រាល




គ-រថយន្តធុនធ្ងន់ និងក្បាលរថយន្តសណ្តោង




ឃ-រ៉ឺម៉ក សីមីរ៉ឺម៉ក



ង-យានយន្តឧករណ៍




ច-ត្រាក់ទ័រ-គោយន្ត




ប្រភេទ ទី៨ : យានយន្តជាកម្មសិទ្ធិបណ្ដោះអាសន្នរបស់ បុគ្គល ឬនិតិបុគ្គល



ប្រភេទ ទី៩ : ផ្លាកលេខបណ្ដោះអាសន្ន

